ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២០/២៣-ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ស៊ីន គឹមស៊ាន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លះ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក**
អាសយដ្ឋាន ៖ ភូមិកំបូល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៦ ៣៨ ៦៨ ០០ /០៧១ ៥៧ ១៥ ៦៦៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | | |
|---|---|---|
| ១- លោក | CYZ | អ្នកគ្រប់គ្រងទូទៅ |
| ២- លោក | ណ ស ភ | រដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក**
អាសយដ្ឋាន ៖ ភូមិកំបូល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៦៩ ៩២ ២០ ០២ /០៧០ ៨៥ ៤២ ៨៨ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | | |
|---|---|---|
| ១- លោក | ស យ | ប្រធានការិយាល័យវិវាទនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(CCAWDU) |
| ២- លោក | ស អ វ | មន្ត្រីច្បាប់នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(CCAWDU) |
| ៣- លោក | គ អ | ប្រធានសហជីព (មូលដ្ឋាន) |



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

៤- លោកស្រី វ វ អនុប្រធានសហជីព (មូលដ្ឋាន)

៥- លោកស្រី ក ស សកម្មជន

៦- លោកស្រី ទសល សកម្មជន

៧- លោកស្រី សសន តំណាងកម្មករ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- តំណាងបងប្អូនកម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលកម្មករនិយោជិតទាំងអស់ធ្វើកូដកម្ម កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ សរុបចំនួនមួយថ្ងៃកន្លះ។ ដោយឡែក ភាគីតំណាងក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនបងប្អូនកម្មករនិយោជិតនៅថ្ងៃធ្វើកូដកម្មបានទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ. ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ ៦៣៩ ក.ប/អក/វក ចុះថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់តំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ស្តីពីស្នើសុំឱ្យក្រុមហ៊ុនដោះស្រាយនូវលក្ខខណ្ឌការងារចំនួន ១១ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានផ្សះផ្សានៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ដោយទទួល

បានលទ្ធផលសះជានឹងគ្នាចំនួន ១០ចំណុច។ ចំណុចមិនសះជាចំនួន ១ចំណុច ដែលនៅសល់ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ ៦៣៩ ក.ប/អក/វក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០២៣។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១ចំណុចនេះ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាបន្ថែមទៀត ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំណុចវិវាទចំនួន ១ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ ឬភស្តុតាង និងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ឬភស្តុតាង។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- កំណត់ហេតុ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក។

២- លក្ខន្តិកៈរបស់ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក បានតម្កល់ទុកលេខ ០០០៤៩០២៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក បានចុះទិដ្ឋាការលេខ ១១២កប/អក/អធក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ ដោយនាយកដ្ឋានអធិការកិច្ចការងារ។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ MOC-៩០៧១១៨៨ ពណ.ចបព ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

៥- គោលការណ៍ផ្តល់ប្រាក់ធ្លោន់មកធ្វើការទៀងទាត់ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក។

៦- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក។

៧- បញ្ជីឈ្មោះកម្មករដែលបានកាត់ប្រាក់នៅថ្ងៃទី២៩ និងថ្ងៃទី៣០ ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក។

៨- ឯកសារជារូបភាព។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចាត់តាំងលោក និងលោក ជាមន្ត្រីដោះស្រាយវិវាទរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ) ដើម្បីចូលរួមអមសម្របសម្រួលនីតិវិធីលើកណើវិវាទក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ ៤៤៦/២៣ ស.ប.ក/វិវាទ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)។

២- លិខិតលេខ ២២៦/២២ ក.ប/វ.ក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ជាអង្គការវិជ្ជាជីវៈមួយ ត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ ៤៧៦/២២ កប/វ.ប.វ.ក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២។

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

៥- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ធ្វើនៅថ្ងៃទី៦ ខែតុលាឆ្នាំ២០២៣ របស់នាយកដ្ឋានវិវាទការងារ។

៦- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ធ្វើនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ របស់នាយកដ្ឋានវិវាទការងារ។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

៨- ពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រុមប្រឹក្សាចរចា តំណាងឱ្យភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងារ ជាមួយនិយោជកនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីប្តឹងនិយោជកក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ករណីមិនអនុវត្តលក្ខខណ្ឌការងារ។

៩- លិខិតពឹងពាក់ និងប្រគល់សិទ្ធិរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ សូមពឹងពាក់ និងប្រគល់សិទ្ធិជូនលោក គអទ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)។

១០- សេចក្តីជូនដំណឹងលេខ ២៩៤ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

១១- ញត្តិទាមទារ និងចាត់តាំងក្រុមប្រឹក្សាចរចា ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ។

១២- ចុងសន្លឹកបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ក្នុងខែកញ្ញា ឆ្នាំ២០២៣។

១៣- ឯកសាររូបភាព។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ ៦៣៩ ក.ប/អក/វក ចុះថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ ០៥៨/២៣ កប/អក/វក/កវក២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១០៤ កប/អក/វក/លកអ ចុះថ្ងៃចន្ទ ២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១០៥ កប/អក/វក/លកអ ចុះថ្ងៃចន្ទ ២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក មានសកម្មភាពចម្បងផ្នែក កាត់ដេរសម្លៀកបំពាក់ និងមានដួលកម្មករនិយោជិតសរុបចំនួន ៣៨៦នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក លេខ ៦៣៩ ក.ប/អក/វក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣)*
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០៥៨/២៣ កប/អក/វក/វកក២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ដែលមានកម្មករនិយោជិតចំនួន ៤នាក់ រួមមាន ៖ ១. គអ ២. ទសល ៣. កស និង ៤. សសន ។

- ញត្តិទាមទារ និងចាត់តាំងក្រុមប្រឹក្សាចរចា ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានភ្ជាប់ជាមួយរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក មានឈ្មោះ និងស្នាមមេដៃកម្មករនិយោជិត សរុបចំនួន ៣០៩នាក់។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗក្នុងអំឡុងពេលកម្មករនិយោជិតទាំងអស់ធ្វើកូដកម្ម កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ សរុបចំនួន មួយថ្ងៃកន្លះ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកសងប្រាក់ឈ្នួលចំនួន ១១.៥៣ដុល្លារអាមេរិក និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ដុល្លារអាមេរិក ជូនកម្មករនិយោជិតចំនួន ៣៨៩នាក់ ដែលបានធ្វើកូដកម្មនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនកន្លះថ្ងៃ) និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនមួយថ្ងៃ)។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ ភាគីកម្មករនិយោជិតបានដាក់សំណើទៅភាគីនិយោជកដើម្បីស្នើសុំប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ៣ថ្ងៃ គឺនៅថ្ងៃទី១១, ថ្ងៃទី១២ និងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ ដើម្បីឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ។ ដោយឡែក ភាគីនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ នៅថ្ងៃទី១១ និងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។ ចំពោះការឈប់សម្រាកនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ គឺកម្មករនិយោជិតត្រូវធ្វើការសងវិញនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ២០២៣ ប៉ុន្តែភាគីកម្មករនិយោជិតមិនឯកភាពធ្វើការថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នោះទេ ពីព្រោះជាថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល។
  - នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ភាគីនិយោជកបានជូនដំណឹងទៅកម្មករនិយោជិតដែលជាប្រធានក្រុម និងប្រធានផ្នែក ដោយអនុញ្ញាតឱ្យកម្មករនិយោជិត ឈប់សម្រាកបុណ្យភ្ជុំបិណ្ឌចំនួន ៣ ថ្ងៃដដែល គឺនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ នៅថ្ងៃទី១១ និងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។ ចំពោះការឈប់សម្រាកនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ គឺកម្មករនិយោជិតត្រូវធ្វើការសងវិញនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣។ ដោយឡែក ភាគីកម្មករនិយោជិតមិនឯកភាពនោះទេ។
  - នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ភាគីនិយោជកបានបង្កើតជម្រើសចំនួន ពីរ ដោយជម្រើសទី១ អនុញ្ញាតឱ្យឈប់សម្រាកតាមច្បាប់ចំនួន ៣ថ្ងៃ គឺនៅថ្ងៃទី១៣, ទី១៤, និងទី១៥ ខែតុលា ឆ្នាំ២០២៣។ ជម្រើសទី២ អនុញ្ញាតឱ្យឈប់សម្រាកចំនួន ២ថ្ងៃ ដោយអនុញ្ញាតឱ្យប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ និងឈប់សម្រាកនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ កម្មករនិយោជិតត្រូវមកធ្វើការសងវិញនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣។ ដោយឡែក ភាគីកម្មករនិយោជិតស្នើសុំប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី១២ និងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ ប៉ុន្តែភាគីនិយោជកមិនឯកភាព។

THE ARBITRATION COUNCIL

- ○ ដោយហេតុថា ភាគីនិយោជក និងភាគីកម្មករនិយោជិតមិនមានការឯកភាពគ្នា ទៅលើការប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌក្នុងខែតុលា ឆ្នាំ២០២៣ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ចាប់ពីវេលាម៉ោង ១០ និង ៤២នាទីព្រឹក រហូតដល់ម៉ោង ៤រសៀល កម្មករនិយោជិតចំនួន ៣៧៣នាក់ បានធ្វើកូដកម្ម ដើម្បីទាមទារប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល។
  - ○ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ កម្មករនិយោជិតចំនួន ៣៨៩ បានធ្វើកូដកម្មម្តងទៀត។
  - ○ ចំពោះថ្ងៃធ្វើកូដកម្មថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនកន្លះថ្ងៃ) និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនមួយថ្ងៃ) និយោជកបានកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតចំនួន ១១.៥៣ដុល្លារអាមេរិក និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ដុល្លារអាមេរិក។
- ភាគីកម្មករនិយោជិតបានលើកឡើងថា នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ភាគីកម្មករនិយោជិតមានឆន្ទៈចូលធ្វើការវិញ ប៉ុន្តែនិយោជកបានបិទទ្វារ ( ឡុកអៅ ) នឹងបានបិទប្រកាសថា កម្មករនិយោជិតណាចង់ធ្វើការវិញចូលក៏ចូលបាន ហើយបើមិនចង់ចូលធ្វើការវិញក៏បានដែរ។ ជាក់ស្តែង និយោជកមិនអនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីពចំនួន ១៣នាក់ ចូលធ្វើការវិញនោះទេ។ ហេតុនេះ កម្មករនិយោជិតទាំងអស់ចេញមកធ្វើកូដកម្មម្តងទៀត។
- ភាគីនិយោជកបានលើកឡើងថា នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ និយោជកមិនបានបិទទ្វារក្រុមហ៊ុននោះទេ ពោលគឺនិយោជកបានបិទប្រកាសឱ្យកម្មករនិយោជិតចូលធ្វើការវិញ ប៉ុន្តែកម្មករនិយោជិតមិនព្រមចូលធ្វើការវិញនោះទេ ហើយមានតែកម្មករនិយោជិតចំនួន ៣០នាក់ប៉ុណ្ណោះ បានចូលធ្វើការវិញ។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ○ ភាគីកម្មករនិយោជិតមានសិទ្ធិប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល នៅក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌ។
  - ○ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ កម្មករនិយោជិតមានឆន្ទៈត្រឡប់ចូលធ្វើការវិញ ប៉ុន្តែនិយោជកបានបិទទ្វារក្រុមហ៊ុន និងមិនឱ្យថ្នាក់ដឹកនាំសហជីពធ្វើការវិញ។
  - ○ កម្មករនិយោជិតធ្វើកូដកម្ម ដោយសារតែនិយោជកមិនអនុញ្ញាតឱ្យកម្មករនិយោជិតប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលរបស់កម្មករនិយោជិត។
  - ○ យោងតាមមាត្រា ១០៣ នៃច្បាប់ស្តីពីការងារ ប្រាក់រង្វាន់ធ្វើការទៀងទាត់ ក៏ជាប្រាក់ឈ្នួលដែរ ហេតុនេះ កម្មករនិយោជិតធ្វើកូដកម្មថ្ងៃណា និយោជកគួរកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់របស់កម្មករនិយោជិតនៅថ្ងៃធ្វើកូដកម្មតែប៉ុណ្ណោះ។ ផ្អែកតាមគោលការណ៍សមធម៌ និយោជកគួរកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ជាសមាមាត្រចំនួន ១.៥ថ្ងៃ ដែលជាថ្ងៃដែលកម្មករនិយោជិតបានធ្វើកូដកម្មតែប៉ុណ្ណោះ។
  - ○ យោងតាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីពបានកំណត់ថា មានតែតុលាការប៉ុណ្ណោះជាអ្នកកំណត់ថា កូដកម្មខុសច្បាប់ ឬមិនខុសច្បាប់។ ជាក់ស្តែង នៅពេលកម្មករនិយោជិតធ្វើកូដកម្មនេះ មិនមានសាលក្រមណាមួយកំណត់ថាកូដកម្មខុសច្បាប់នោះទេ។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយហេតុថា ៖
  - ○ ភាគីកម្មករនិយោជិតបានធ្វើកូដកម្មដោយខុសច្បាប់ ហេតុនេះ និយោជកមិនអាចផ្តល់ជូនប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់បាននោះទេ។

- យោងតាមច្បាប់ស្តីពីការងារបានកំណត់ថា កម្មករនិយោជិតដែលធ្វើកូដកម្មខុសច្បាប់នោះ កម្មករនិយោជិតមិនមានសិទ្ធិទទួលបានប្រាក់ឈ្នួលនោះទេ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងប្រាក់ឈ្នួលចំនួន ១១.៥៣ដុល្លារអាមេរិក និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ដុល្លារអាមេរិក ជូនកម្មករនិយោជិតចំនួន ៣៨៩នាក់ ដែលបានធ្វើកូដកម្មនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនកន្លះថ្ងៃ) និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនមួយថ្ងៃ)

មុននឹងធ្វើការពិចារណាលើការទាមទារក្នុងចំណុចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាអំពីចំនួនដើមបណ្តឹង ដូចខាងក្រោម ៖

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"*។

លើសពីនេះទៀត ប្រការ ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម។"*។

យោងតាមប្រការ ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២២៣/១៦-យូនីកតា ថេកណូឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និងសណ្ឋាគារ, លេខ ២៣៧/១៦-ហ្សិណាដាយយ៉ុង (ខេមបូឌា) អេឡិចត្រូនិច និង លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០៥៨/២៣ កប/អក/វក/វកក២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ដែលមានកម្មករនិយោជិតចំនួន ៤ នាក់ រួមមាន ៖ ១. គអ ២. ទសល ៣. កស និង ៤. សសន ។ នៅថ្ងៃសវនាការអាជ្ញាកណ្តាល ក៏មានវត្តមានរបស់តំណាងកម្មករនិយោជិតទាំង ៤នាក់ ខាងលើផង

ដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ៥នាក់ មានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិតនៃក្រុម ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលស្របតាមប្រការ ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

ប្រការ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬអ្នកតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។"*

យោងតាមប្រការ១៩ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួន ក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាតែបុគ្គលនោះ ទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦១/០៩-សិប្បកម្ម ព្រែកត្រែង, លេខ ៤៣/១០-ម៉ឹង ជឿន, លេខ ១៤៤/១២-អ៊ី ហ្គាមេន និងលេខ ១២០/១៥-ក័ហ្វិក គ្រាស់ ប្រាយវេត ខូអិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសនោការ ភាគីកម្មករនិយោជិតបានអះអាងថា កម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចវិវាទនេះមានចំនួន ៣៨៩នាក់ ប៉ុន្តែ ផ្អែកតាមបញ្ជីឈ្មោះកម្មករនិយោជិតដែលបានផ្តិតស្នាមមេដៃទាមទារនៅក្នុងញត្តិទាមទារ និងចាត់តាំងក្រុមប្រឹក្សាចរចា ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានភ្ជាប់ជាមួយរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក មានឈ្មោះ និងស្នាមមេដៃកម្មករនិយោជិត សរុបចំនួន ៣០៩នាក់ តែប៉ុណ្ណោះ។ ហេតុនេះ យោងតាមការបកស្រាយប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ. ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទនេះ សម្រាប់កម្មករនិយោជិតចំនួន ៣០៩នាក់ ដែលជាដើមបណ្តឹង។ *(សូមមើលឧបសម្ព័ន្ធ បញ្ជីឈ្មោះកម្មករនិយោជិតដែលបានផ្តិតមេដៃទាមទារ)*

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្នុងអំឡុងពេលកូដកម្មនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនកន្លះថ្ងៃ) និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនមួយថ្ងៃ) កម្មករនិយោជិតចំនួន ៣០៩ នាក់ មានសិទ្ធិទទួលបានប្រាក់ឈ្នួលចំនួន ១១.៥៣ដុល្លារអាមេរិក និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ដុល្លារអាមេរិកដែរឬទេ?**

មាត្រា ៣២៤ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ការធ្វើកូដកម្ម ត្រូវជូនដំណឹងមុន ក្នុងរយៈពេលយ៉ាងតិចប្រាំពីរថ្ងៃ គិតតែថ្ងៃធ្វើការ ហើយត្រូវតម្កល់ទុកនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។..."*

កថាខណ្ឌទី៤ មាត្រា ៣២០ នៃច្បាប់ស្តីពីការងារ ដដែលចែងថា ៖ *"សិទ្ធិធ្វើកូដកម្មអាចអនុវត្តទៅបានលុះត្រាតែបានប្រើប្រាស់អស់លទ្ធភាពក្នុងការដោះស្រាយជំលោះដោយមធ្យោបាយសន្តិវិធីជាមួយនិយោជក។"*

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការបកស្រាយមាត្រា ៣២០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការងារថា ៖ *"...កម្មករនិយោជិតមិនទាន់បានប្រើអស់លទ្ធភាពក្នុងការដោះស្រាយវិវាទ ស្របតាមមាត្រា ៣២០ កថាខណ្ឌទី៤ ឡើយ ពីព្រោះថា កម្មករនិយោជិតបានធ្វើកូដកម្ម មុននីតិវិធីដោះស្រាយនៃការចរចា និងផ្សះផ្សារបស់អធិការការងារ និងតាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជាស្ថាប័នដោះស្រាយវិវាទ*

ARBITRATION COUNCIL

*ការងាររួមដោយសន្តិវិធី...”។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១០/០៧-នូវឌប ហេតុផលនៃចំណុចវិវាទទី៣, លេខ ២៧/១០-ហាត អ៊ិនជើប្រាយ, លេខ ០១៨/១៧-ខេមបូ យូនីសូល អិលធីឌី ហេតុផលនៃចំណុចវិវាទទី៣, លេខ ០២៣/១៨-ហ្វ៊ីសាន់នី ហ្គាម៉ិន ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១, និងលេខ ០១០/១៩-ឡុង វិចថូរី អ៊ិនជើណេសិនណាល (ខេមបូឌា) លីមីធីត)*

ផ្អែកតាមអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា នៅថ្ងៃទី២៨ និងថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣ ភាគីកម្មករនិយោជិតបានស្នើសុំទៅភាគីនិយោជកក្នុងការប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលមុន និងក្រោយពេលឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ ប៉ុន្តែភាគីទាំងពីរមិនមានការឯកភាពគ្នាទៅលើការប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនោះទេ។ កម្មករនិយោជិតបានធ្វើកូដកម្ម នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ចាប់ពីវេលាម៉ោង ១០ និង ៤២នាទីព្រឹក ដោយមានកម្មករនិយោជិតចំនួន ៣៧៣នាក់ ចូលរួម និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ដោយមានកម្មករនិយោជិតចំនួន ៣៨៩នាក់ ចូលរួម។ ក្នុងករណីនេះ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលពិនិត្យឃើញថា កម្មករនិយោជិតបានធ្វើកូដកម្ម ដោយមិនបានជូនដំណឹងជាមុនដល់និយោជកស្របតាមមាត្រា ៣២៤ នៃច្បាប់ស្តីពីការងារ និងមិនបានព្យាយាមឱ្យអស់លទ្ធភាពក្នុងការដោះស្រាយវិវាទការងារតាមរយៈការចរចា និងផ្សះផ្សារបស់អធិការការងារ និងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមកថាខណ្ឌទី៤ មាត្រា ៣២០ នៃច្បាប់ស្តីពីការងារនោះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមិនបានអនុវត្តសិទ្ធិធ្វើកូដកម្មឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់តម្រូវនោះទេ។

លើសពីនេះ កថាខណ្ឌទី១ មាត្រា ៣៣២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម។ ក្នុងអំឡុងពេលនៃកូដកម្ម តាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ”។*

ចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារ ដដែលចែងថា ៖ *"ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗ នៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោ-ជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទបញ្ញត្តិផ្ទុយដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត”។*

នៅក្នុងសំណុំរឿងលេខ ២៧/១០-ហាត អ៊ិនជើប្រាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយថា ៖ *“ផ្អែកតាមខ្លឹមសារនៃមាត្រា ៣៣២ និងមាត្រា ៧២ (1) នៃច្បាប់ស្តីពីការងារ គឺនៅថ្ងៃ ឬខែណា ដែលកម្មករនិយោជិតធ្វើកូដកម្ម ទោះបីកូដកម្មត្រឹមត្រូវតាមនីតិវិធីច្បាប់ ឬមិនត្រឹមត្រូវតាមនីតិវិធីច្បាប់ក៏ដោយ និយោជកមិនតម្រូវឱ្យផ្តល់ប្រាក់ឈ្នួល ឬប្រាក់រង្វាន់ដល់កម្មករនិយោជិតទេ ក្នុងអំឡុងពេលថ្ងៃណា ឬខែណា ដែលបានធ្វើកូដកម្មនោះ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនជាប់កាតព្វកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតដែលជាកូដករ ក្នុងអំឡុងពេលធ្វើកូដកម្មឡើយ។” (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៩/០៥-អូ សេ អង់ ហ្គាមិន ហេតុផលនៃចំណុចវិវាទទី៣, លេខ ០០៩/១៤-ស៊ីណូ ហ្គាមេន, លេខ ០៥០/១៥-ភ៉ាន់ធីជ រីវើរ ថេកស្តាយ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៣, លេខ ២១៤/១៦-ដុងឌូ ថេកស្តាយ (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៧ និង លេខ ២២៣/១៦-យូនីគា ថេកណូឡូជី (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១៩)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ២៩៥/១៤-ស៊ីជាប់បែលយូខេអេជ ហ្គាមេន (ខេមបូឌា) លីមីធីត ហេតុផលនៃចំណុចវិវាទទី២ បានបកស្រាយថា កម្មករនិយោជិតបានធ្វើកូដកម្មមិនត្រឹមត្រូវតាម

នីតិវិធីច្បាប់ កម្មករនិយោជិតមិនមានសិទ្ធិទទួលបានប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលកូដកម្មឡើយ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០២៨/១៤-ណាហ្គាវើលដ៍ ហេតុផលនៃចំណុចវិវាទទី៤)*

ជាមួយគ្នានេះ ចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ២៣០ ក.ប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ចែងថា ៖ *"កម្មករនិយោជិតដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃនៃថ្ងៃធ្វើការក្នុងខែនីមួយៗ ដោយគ្មានអវត្តមាន ត្រូវទទួលបានប្រាក់រង្វាន់យ៉ាងតិចចំនួន ១០(ដប់) ដុល្លារអាមេរិក ក្នុងមួយខែ"*។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចថា ៖ *"កម្មករនិយោជិតដែលធ្វើកូដកម្មមិនស្របទៅតាមនីតិវិធីច្បាប់ស្តីពីការងារ គឺមិនមកធ្វើការទៀងទាត់ទេ ដូច្នេះ កម្មករនិយោជិតនោះមិនអាចទទួលបានប្រាក់រង្វាន់ធ្វើការទៀងទាត់ទេ"* *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤/០៣-លីដា ហេតុផលនៃចំណុចវិវាទទី០១, លេខ ១៥/០៤-ឡាក់គី ហ្សូន ហេតុផលនៃចំណុចវិវាទទី០៤, លេខ ០៧/០៥-កូកាកូឡា ហេតុផលនៃចំណុចវិវាទទី០៤, លេខ ៦៣/០៧-ភ្នំពេញ ហ្គាមេន, លេខ ៥៤/០៨-ចុងយ៉ូវ ហេតុផលនៃចំណុចវិវាទទី០៣, លេខ ៨១/០៨-ក្លូបល អាប៉ារ៉ែល ហេតុផលនៃចំណុចវិវាទទី០១ និងទី០២, លេខ ១១៨/១០-មេនហាតធេន ហេតុផលនៃចំណុចវិវាទទី០២, លេខ ២០៤/១២-ខេមបូ ខូថប ហេតុផលនៃចំណុចវិវាទទី១២ និងលេខ ០៩០/១៥-ក័រហ្វិក គ្រោស៍ ប្រាយវេត ខូអិលធីឌី ហេតុផលនៃចំណុចវិវាទ)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមការបកស្រាយខាងលើ កូដកម្ម នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ចាប់ពីវេលាម៉ោង ១០ និង ៤២នាទីព្រឹក និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ជាកូដកម្ម មិនស្របទៅតាមនីតិវិធីច្បាប់ ហេតុនេះ កម្មករនិយោជិតដែលចូលរួមធ្វើកូដកម្មមិនស្របតាមនីតិវិធីច្បាប់ មិនមានសិទ្ធិទទួលបានប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នោះទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងប្រាក់ឈ្នួលចំនួន ១១.៥៣ដុល្លារអាមេរិក និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ដុល្លារអាមេរិក ជូនកម្មករនិយោជិតចំនួន ៣០៩នាក់ ដែលបានធ្វើកូដកម្មនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនកន្លះថ្ងៃ) និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនមួយថ្ងៃ)។

យោងតាមការបង្ហាញកស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងប្រាក់ឈ្នួលចំនួន ១១.៥៣ដុល្លារអាមេរិក និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ដុល្លារអាមេរិក ជូនកម្មករនិយោជិតចំនួន ៣០៩នាក់ ដែលបានធ្វើកូដកម្មនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនកន្លះថ្ងៃ) និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ (ចំនួនមួយថ្ងៃ)។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គឹមសាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា ៖ ------------------------------